# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីប្រកាសព័ត៌មាន

ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥នេះ មានជនអនាមិកមួយចំនួនបានដើរបំផុសនូវពាក្យចចាមអារ៉ាម ដោយគ្មានឯកសារយោង និងគ្មានតំណាងពិតប្រាកដ រហូតបង្កឱ្យមានភាពជ្រួលច្របល់ របួសស្នាម សកម្មភាពហិង្សា ដូចជាការគប់បំផ្លាញទ្រព្យសម្បត្តិរដ្ឋនិងរោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមែនហាតធេន និងតំបន់សេដ្ឋកិច្ចពិសេស តាយសេង ក្រុងបាវិត ខេត្តស្វាយរៀង។ បើទោះបីជាអំពើហិង្សាបានកើតឡើង ហើយបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍កម្មករនិយោជិត និងដំណើរការផលិតកម្មរបស់រោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចទាំងពីរក៏ដោយ ក៏ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះអាជ្ញាធរមានសមត្ថកិច្ចបានខិតខំអត់ធ្មត់ខ្ពស់បំផុត និងបានប្រើប្រាស់គ្រប់មធ្យោបាយសន្តិវិធីនានា សំដៅស្តារនូវសណ្តាប់ធ្នាប់ និងប្រក្រតីភាពក្នុងតំបន់សេដ្ឋកិច្ចពិសេសទាំងពីរឡើងវិញ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានការសោកស្តាយចំពោះហេតុការណ៍ហិង្សានេះ និងសូមថ្កោលទោសយ៉ាងខ្លាំងក្លាបំផុតចំពោះជនទុច្ចរិតដែលជាអ្នកញុះញង់ និងនៅពីក្រោយនៃហេតុការណ៍នេះ ព្រមទាំងសូមគាំទ្រយ៉ាងពេញទំហឹងចំពោះចំណាត់ការប្រកបដោយភាពអត់ធ្មត់ និងវិជ្ជាជីវៈខ្ពស់របស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការទប់ស្កាត់ការប៉ុនប៉ងធ្វើវិច្ឆេទកម្មសេដ្ឋកិច្ចដោយជនទុច្ចរិតមួយក្រុមតូចដែលមានបំណងបំផ្លាញការងារប្រចាំថ្ងៃរបស់បងប្អូនកម្មករនិយោជិតផង ទម្លាក់កំហុសមកលើរាជរដ្ឋាភិបាលផង។

ក្រសួងសូមធ្វើការគូសបញ្ជាក់ជូនសាធារណជន បងប្អូនកម្មករនិយោជិត និងអង្គការវិជ្ជាជីវៈទាំងអស់ថា៖

- សកម្មភាពហិង្សានេះជាអំពើល្មើសច្បាប់ មិនមែនជាកូដកម្ម ដូចមានចែងក្នុងជំពូកទី១៣ នៃច្បាប់ស្តីពីការងារ ឬបាតុកម្មដោយសន្តិវិធី ដូចមានចែងក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីនោះឡើយ
- សកម្មភាពហិង្សានេះ គឺបានកើតឡើងចំពេលដែលអ្នកបញ្ជាទិញអន្តរជាតិកំពុងធ្វើការប្រៀបធៀបកម្ពុជា ជាមួយបណ្តាប្រទេសផ្សេងទៀត និងត្រូវសម្រេចថាដាក់ផែនការបញ្ជាទិញប្រចាំឆ្នាំពីកម្ពុជាចំនួនប៉ុន្មាន? សកម្មភាពហិង្សា និងភាពជ្រួលច្របល់នេះគឺធ្វើឡើងក្នុងគោលបំណងឱ្យអ្នកវិនិយោគ និងអ្នកបញ្ជាទិញបាត់ជំនឿក្នុងការវិនិយោគនៅកម្ពុជា និងដកការបញ្ជាទិញពីកម្ពុជា
- កន្លងមក តាមរយៈជំនួយបច្ចេកទេសពីអង្គការអន្តរជាតិខាងការងារ (ILO) ភាគីសហជីព និងភាគីនិយោជកទាំងអស់នៅកម្ពុជាបានឯកភាពគ្នាជាឯកច្ឆន្ទកំណត់ឱ្យមានយន្តការចចារប្រាក់ឈ្នួលអប្បបរមា និងមានលក្ខណវិនិច្ឆ័យក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាច្បាស់លាស់។ តាមរយៈយន្តការ និងលក្ខណវិនិច្ឆ័យនេះ ចាប់ពីខែកក្កដា ឆ្នាំ២០១៥នេះ ភាគីសហជីព និងភាគីនិយោជកបានធ្វើការចចារគ្នាអស់រយៈពេលជាង៣ខែ។ យោងលើការចចារនេះ ក្រសួងបានចេញប្រកាសលេខ៤០៩/១៥ ក.ប/ប្រ.ក កំណត់រួចហើយថាចាប់ពីខែមករា ឆ្នាំ២០១៦ នេះតទៅ បងប្អូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនឹងទទួលបានប្រាក់ឈ្នួលអប្បបរមាចំនួន១៤០ដុល្លារអាមេរិកក្នុងមួយខែ។

អាស្រ័យហេតុនេះ ក្រសួងសូមធ្វើការអំពាវនាវដល់សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិត និងអង្គការវិជ្ជាជីវៈទាំងអស់ សូមមេត្តារក្សាភាពស្ងៀមស្ងាត់ ភាពហ្មឹងហ្មរ និងសូមបង្កើនការប្រុងប្រយ័ត្នចំពោះ ពាក្យចចាមអារ៉ាមនានាដែលគ្មានឯកសារយោងច្បាស់លាស់។ រាល់ការតវ៉ា ឬទាមទារណាមួយ សូមបងប្អូនប្រកាន់ខ្ជាប់នូវនីតិវិធីស្របច្បាប់ និងជ្រើសរើសតំណាងត្រឹមត្រូវពិតប្រាកដ ដើម្បីទំនាក់ទំនងស្នើសុំការអន្តរាគមន៍មកក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ត្រីទទួលបន្ទុកប្រចាំការរបស់ក្រសួងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទាំងនោះ។

*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ ទូរសារៈ(០២៣)៨... ៦៩*